**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ០៧.សសរ**

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួងសម្រាប់ដឹកនាំ ត្រួតពិនិត្យ និងវាយតម្លៃ លើការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ឆ្នាំ២០២០

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា២៦ មាត្រា២៧ មាត្រា២៨ និងមាត្រា២៩ និងបំពេញមាត្រា២៩ ស្ទួន នៃអនុក្រឹត្យលេខ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍



www.pheakdeylaw.com

- បានឃើញគោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានឆ្នាំ២០២០ ដែលត្រូវបានដាក់ឱ្យប្រើប្រាស់ដោយសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៣៧៣ សជណ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

## សម្រេច

**ប្រការ ១.-**

ត្រូវបង្កើតគណៈកម្មការអន្តរក្រសួងសម្រាប់ដឹកនាំ ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១ | ឯកឧត្តម **ត្រាំ អ៊ីវតឹក** | រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | ប្រធាន |
| ២ | ឯកឧត្តម **ភាន ច័ន្ទមេត្តា** | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | អនុប្រធាន |
| ៣ | ឯកឧត្តម **ឌុច សុវណ្ណារី** | រដ្ឋលេខាធិការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច | សមាជិក |
| ៤ | ឯកឧត្តម **ម៉ែន សុផល** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៥ | ឯកឧត្តម **សៅ ជីវ័ន្ត** | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៦ | ឯកឧត្តម **ឌៃ ម៉ុនឈឿន** | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៧ | ឯកឧត្តម **អ៊ុក ប្រជា** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៨ | ឯកឧត្តម **សុះ មុះសិន** | រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា | សមាជិក |
| ៩ | ឯកឧត្តម **គន់ ម៉ាន់ថារ៉ា** | រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម | សមាជិក |
| ១០ | ឯកឧត្តម **ភឹមរ័ត្ន វិសិដ្ឋ** | នាយកខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន** ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១១ | ឯកឧត្តម **ខូច មករា** | អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ១២ | ឯ.ឧ នាយឧត្តមសេនីយ៍ **ឃុន ឌុច** | អនុរដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ១៣ | ឯកឧត្តម **ជីន ម៉ុនថេន** | អនុរដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៤ | ឯកឧត្តម **ផាន់ ផល្លា** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១៥ | ឯកឧត្តម **សេរី ជំនះ** | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៦ | ឯកឧត្តម **ជិន ម៉ាលីន** | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ១៧ | ឯកឧត្តម **ម៉ា ស៊ុនហួត** | អនុរដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |



www.pheakdeylaw.com

| | | | |
|---|---|---|---|
| ១៨ | ឯកឧត្តម **ហ៊ី ទីរៈ** | អនុរដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | សមាជិក |
| ១៩ | ឯកឧត្តម **សុខ គុខហាប់** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ២០ | លោកជំទាវ **ឡុង សុផល្លី** | អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី | សមាជិក |
| ២១ | លោកជំទាវ **សៅ ស្រីពៅ** | អនុរដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ២២ | ឯកឧត្តម **គុល ញ៉ក់** | អគ្គនាយកនៃអគ្គនាយកដ្ឋានប្រៃសណីយ៍និងទូរគមនាគមន៍នៃក្រសួង ប.ទ. | លេខាធិការ |
| ២៣ | ឯកឧត្តម **ជុន ទ៉ាត** | អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាននៃក្រសួង ប.ទ. | សមាជិក |
| ២៤ | ឯកឧត្តម **សេខ សុភាព** | ប្រធានវិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាននៃក្រសួង ប.ទ. | សមាជិក |
| ២៥ | ឯកឧត្តម **ពេជ្រ ចិន្ដាគន្ធី** | អគ្គនាយកនៃអគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈនៃក្រសួងមុខងារសាធារណៈ | សមាជិក |
| ២៦ | ឯកឧត្តម **ស៊ុយ ឌីម៉ង់** | អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅនៃក្រសួងរ៉ែនិងថាមពល | សមាជិក |
| ២៧ | ឯកឧត្តម **ម៉ុត មូនុត** | ប្រតិភូរាជរដ្ឋាភិបាល ក្រសួងព័ត៌មាន | សមាជិក |
| ២៨ | លោក **ប្រាក់ ថាចរមិដា** | អគ្គលេខាធិការរងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ២៩ | លោក **គ្រុយ ទាសនា** | អគ្គលេខាធិការរងនិងជាប្រធាននាយកដ្ឋានព័ត៌មានវិទ្យា នៃធនាគារជាតិនៃកម្ពុជា | សមាជិក |
| ៣០ | លោក **អ៊ុខ ទិសិដ្ឋ** | អគ្គលេខាធិការរងនៃក្រុមប្រឹក្សាជាតិ វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា | សមាជិក |
| ៣១ | លោក **ឌឹខ ដារ៉ា** | ប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងសរុបនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៣២ | លោក **សោម សាឌុច** | ប្រធាននាយកដ្ឋានព័ត៌មានវិទ្យានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា | សមាជិក |
| ៣៣ | លោកស្រីបណ្ឌិត **សុខ មូទី** | ទីប្រឹក្សាទូរគមនាគមន៍កម្ពុជា | សមាជិក |
| ៣៤ | លោកឱសថការី **លុក សាគី** | ប្រធានការិយាល័យបញ្ជីកានៃនាយកដ្ឋានឱសថ ចំណីអាហារ និងបរិក្ខារពេទ្យ នៃក្រសួងសុខាភិបាល | សមាជិក |



www.pheakdeylaw.com

**ប្រការ ២.-**

គណៈកម្មការអន្តរក្រសួងសម្រាប់ដឹកនាំ ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន មានមុខងារនិងភារកិច្ចដូចខាងក្រោម៖

- ដឹកនាំ ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- លើកសំណើនិងផ្តល់យោបល់ជូនរាជរដ្ឋាភិបាល ដើម្បីធ្វើការសម្រេចចិត្តក្នុងការដោះស្រាយបញ្ហាប្រឈមចំពោះមុខដែលបានកើតឡើងនៅក្នុងពេលអនុវត្ត
- រៀបចំផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីគោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដើម្បីអនុវត្តប្រកបដោយប្រសិទ្ធភាព
- សហការជាមួយអង្គការអន្តរជាតិនិងដៃគូអភិវឌ្ឍន៍នានា ដើម្បីកៀរគរជំនួយបច្ចេកទេសនិងថវិកាសម្រាប់អនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឱ្យកាន់តែមានប្រសិទ្ធភាព
- សម្របសម្រួលដំណើរការពិគ្រោះយោបល់នានា ទាំងកម្រិតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអន្តរជាតិទាក់ទងនិងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- រៀបចំរបាយការណ៍ប្រចាំ ០៦ (ប្រាំមួយ) ខែ ជូនរាជរដ្ឋាភិបាល ស្តីពីវឌ្ឍនភាពនិងបញ្ហាប្រឈមនានាក្នុងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដោយផ្អែកលើគោលដៅនិងសូចនាករដែលបានកំណត់ក្នុងគោលនយោបាយនេះ។

**ប្រការ ៣.-**

គណៈកម្មការអន្តរក្រសួងសម្រាប់ដឹកនាំ ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន មានសិទ្ធិបង្កើតក្រុមការងារជំនាញបច្ចេកទេសអន្តរក្រសួង និងអាចប្រើប្រាស់មន្ត្រីរបស់ស្ថាប័នសាមី ដើម្បីចូលរួមអនុវត្តភារកិច្ចរបស់គណៈកម្មការអន្តរក្រសួង ដូចមានចែងក្នុងប្រការ២។

**ប្រការ ៤.-**

គណៈកម្មការអន្តរក្រសួងសម្រាប់ដឹកនាំ ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន មានសិទ្ធិអញ្ជើញមន្ត្រីជំនាញជាតិនិងអន្តរជាតិមកចូលរួមផ្តល់យោបល់បន្ថែមលើការងារនេះ។

**ប្រការ ៥.-**

អនុប្រធាន សមាជិក និងលេខាធិការនៃគណៈកម្មការអន្តរក្រសួងសម្រាប់ដឹកនាំ ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធាន។ ប្រធានអាចប្រគល់ភារកិច្ចដឹកនាំកិច្ចប្រជុំជូនអនុប្រធាន ក្នុងករណីមានធុរៈ។



www.pheakdeylaw.com

**ប្រការ ៦.-**

សមាជិកគណៈកម្មការអន្តរក្រសួងសម្រាប់ដឹកនាំ ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន និងក្រុមការងារជំនាញបច្ចេកទេស អាចប្រើប្រាស់ថវិការបស់ស្ថាប័នសាមី ដើម្បីបំពេញបេសកកម្ម។

**ប្រការ ៧.-**

គណៈកម្មការអន្តរក្រសួងសម្រាប់ដឹកនាំ ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍-បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន មានសិទ្ធិប្រើត្រារបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

**ប្រការ ៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០១៧

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com